E20 - 16

# រឿងនិទាន ស្ដីពីសហគមន៍នេសាទមួយ




គំរោងការគ្រប់គ្រងជលផលនៅអាងទឹកនៃអាងទន្លេមេគង្គជំហានទី២

ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ

នាយកដ្ឋានជលផល

## រឿងនិទាន

# ស្តីពី សហគមន៍នេសាទមួយ

ឧបត្ថម្ភដោយ

**នាយកដ្ឋានជលផល** **គណៈកម្មការទន្លេមេគង្គ**

រៀបចំដោយ

**ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទនៃនាយកដ្ឋានជលផល និង**
**គ្រោងការគ្រប់គ្រងជលផលនៅអាងទឹកនៃអាងទន្លេមេគង្គជំហានទី២**
**នៃគណៈកម្មការទន្លេមេគង្គ**


អាស័យដ្ឋានៈ

#១៨៦ មហាវិថីព្រះនរោត្តម ទូរសព្ទ័លេខៈ (៨៥៥-២៣) ២១០ ១៥៤

ខណ្ឌចំការមន ទីក្រុងភ្នំពេញ ទូរសារលេខៈ (៨៥៥-២៣) ២១០ ១៥៤


ខែ កញ្ញា ឆ្នាំ ២០០២

# បុព្វកថា

សៀវភៅរឿងត្លុកដែលនិទានអំពីដំណើរការរៀបចំ និង គ្រប់គ្រងសហគមន៍នេសាទនេះ ត្រូវបានចងក្រងឡើងរួមគ្នាដោយនាយកដ្ឋានជលផល និងគ្រោងការគ្រប់គ្រងជលផលនៅអាងទឹកនៃអាងទន្លេមេគង្គនៅកម្ពុជា ដើម្បីបំពេញនូវសេចក្តីត្រូវការបន្ទាន់នៅតាមមូលដ្ឋានជាក់ស្តែង ។ ស្របពេលនឹងកំណែទំរង់វិស័យជលផលរបស់រាជរដ្ឋាភិបាលដែលបានលុប និង កាត់បន្ថយផ្ទៃឡូត៍នេសាទជាង ៥០ ភាគរយ ជូនប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ ការគ្រប់គ្រងតាមបែបសហគមន៍ជាមធ្យោបាយ រឺ ដំណោះស្រាយសមស្របមួយ ដើម្បីប្រើប្រាស់ និង អភិវឌ្ឍន៍ធនធានជលផលឱ្យមាននិរន្តរភាព សមធម៌ និង ប្រសិទ្ធិភាព។

យើងខ្ញុំសង្ឃឹមថាសៀវភៅនេះ នឹងបានផ្សព្វផ្សាយទៅដល់ភូមិជាច្រើនដែលគ្មានគំរោងរដ្ឋាភិបាលរឺក្រៅរដ្ឋាភិបាលជួយ ហើយនឹងអាចជួយឱ្យប្រជាជននៅតាមភូមិទាំងនោះ យល់ពីដំណើរការរៀបចំសហគមន៍នេសាទ ដើម្បីជាជំនួយដល់ពួកគេក្នុងការរៀបចំបង្កើតសហគមន៍ដោយខ្លួនឯងបាន ទៅតាមស្ថានភាពជាក់ស្តែងនៅតាមតំបន់រៀងៗខ្លួន។

ខ្ញុំសូមឆ្លៀតយកឱកាសនេះ ដើម្បីផ្តល់ជាកំលាំងចិត្តដល់អ្នកទាំងឡាយណាដែលចង់បង្កើតសហគមន៍នេសាទឱ្យបន្តធ្វើតាមផែនការរបស់ខ្លួន និង សូមឱ្យអ្នកទាំងនោះមានការអត់ធ្មត់ ការលះបង់ខ្ពស់ ដើម្បីទទួលបានជោគជ័យក្នុងការខិតខំប្រឹងប្រែងរបស់ខ្លួន។

AIDOC
Code: 142-023
Date:
Donated by:

ភ្នំពេញ ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០២

**ប្រធាននាយកដ្ឋានជលផល**

**ណៅ ធួក**

# សេចក្តីផ្តើម

នៅចុងឆ្នាំ ២០០០ ផ្ទៃឡូត៍ជាង ៥០ ភាគរយបានត្រូវលប់ និងកាត់បន្ថយ ដើម្បីប្រគល់ឱ្យប្រជានេសាទធ្វើនេសាទជាលក្ខណៈគ្រួសារ និង គ្រប់គ្រងតាមបែបសហគមន៍ ។ ប្រជាពលរដ្ឋនៅតាមភូមិជាច្រើន ចង់បានការគ្រប់គ្រងតាមបែបសហគមន៍នេះ ក៏ប៉ុន្តែពួកគេ មិនដឹងពីបែបបទនៃកាបង្កើតសហគមន៍នេសាទនេះទេ ។

សៀវភៅនេះ ត្រូវបានចងក្រងឡើង ដើម្បីបំពេញសេចក្តីត្រូវការរបស់ពួកគាត់ ជាពិសេសសំរាប់ប្រជានេសាទដែលចង់បង្កើតសហគមន៍នេសាទ នៅតាមតំបន់ឆ្ងាយដាច់ស្រយាល ដែលអង្គការ រឺ ស្ថាប័នរដ្ឋាភិបាលមិនអាចទៅជួយដល់ទីកន្លែងបាន ។ សៀវភៅនេះ បានរៀបរាងឡើងជារបៀបរឿងត្លុកដែលនិទាន ស្តីពីដំណើរការសាមញ្ញនៃការរៀបចំសហគមន៍នេសាទមួយដោយផ្អែកទៅតាមគោលការណ៍ណែនាំបណ្តោះអាសន្នរបស់នាយកដ្ឋានជលផល ។ រឿងត្លុកនេះ បានបង្ហាញសំខាន់ ពីមូលហេតុដែលនាំអោយប្រជានេសាទចាប់អារម្មណ៍ និង មានគំនិតបង្កើតសហគមន៍នេសាទ ហើយពួកគាត់បានស្រុះស្រួល និង ឯកភាពគ្នារៀបចំបង្កើតសហគមន៍នេះឡើង នៅក្នុងតំបន់របស់ពួកគាត់ ។ ព្រមជាមួយនេះ ផែនការគ្រប់គ្រងសហគមន៍ក៏ត្រូវបានធ្វើ និង អនុវត្តដោយពួកគាត់ផ្ទាល់ ដោយមានការគាំទ្រ ទំនាក់ទំនង និងសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរដែនដី និងស្ថាប័នជំនាញដែលពាក់ព័ន្ធ ដើម្បីសំរេច នូវគោលដៅនៃការគ្រប់គ្រង និង ប្រើប្រាស់ធនធានជលផលឱ្យមាននិរន្តភាព ។

នៅក្នុងសៀវភៅនេះ ក៏បានភ្ជាប់នូវបញ្ជីគំរោង និង អង្គការ ដែលធ្វើការជាប់ទាក់ទងជាមួយការអភិវឌ្ឍន៍សហគមន៍នេសាទ នៅតាមបណ្តាខេត្ត ដើម្បីផ្តល់ជាពត៌មានផងដែរ ។ លើសពីនេះ ក៏មានគោលការណ៍ណែនាំសាមញ្ញសំរាប់ធ្វើលក្ខនិកៈ និងបទបញ្ញត្តិ និង គំរូនៃការធ្វើផែនការសកម្មភាពនៃសហគមន៍ដែលធ្វើដោយសហគមន៍នេសាទអាងទឹកបឹងជន្លេន នៅស្រុកមុខកំពូល ខេត្តកណ្តាល ភ្ជាប់ជាមួយផងដែរ ។

# វគ្គទី ១

# មូលហេតុ

# ដែលនាំអោយមានគំនិតបង្កើតសហគមន៍






## របៀបនេសាទដែលបំផ្លិចបំផ្លាញពូជត្រីកំពុងរីករាលដាល




## ទំនាស់ពីសិទ្ធនៃការប្រើប្រាស់ដែននេសាទ



# អ្នកនេសាទកើនឡើងផលចាប់ថយចុះ



## ការទទួលស្គាល់បញ្ហា គឺជាផ្លូវល្អក្នុងការចាប់ផ្តើមរៀបចំសហគមន៍



# វគ្គទី ២

# ដំណើរការរៀបចំបង្កើតសហគមន៍នេសាទ





## ការស្វែងរកអ្នកមានបទពិសោធន៍ វិបញ្ហាដូចគ្នា និង ផ្សព្វផ្សាយពីគោលបំណង នៃការបង្កើតសហគមន៍ ជាផលចំណេញដ៏សំខាន់ក្នុងការគាំទ្រសហគមន៍



# បង្កើតភាពជឿទុកចិត្ត ចំណេះដឹង និង បទពិសោធន៍ក្នុងស្រុក ស្នើសុំជំនួយបើអាចធ្វើទៅបាន



# ការប្រជុំគ្នាជាលើកដំបូងរបស់ប្រជានេសាទ ដើម្បីពិភាក្សារកចំណុចឯកភាពរួម



## វគ្គទី ៣

# ធ្វើផែនការ និង អនុវត្តផែនការ







ការរិះរកបទពិសោធន៍ជាក់ស្តែង និងគំនិតផ្តួចផ្តើមរួមគ្នា ដើម្បីដោះស្រាយបញ្ហា និង ជួយបង្កើតសេចក្តីទុកចិត្ត ជាវិធីសាស្ត្រដ៏ល្អមួយដែលទទួលស្គាល់ជារួម ហើយលើក ជាផែនការសកម្មភាព និងអនុវត្ត ដើម្បីសំរេចគោលដៅរបស់សហគមន៍



# ការប្រគល់ភារកិច្ចអោយសមាជិកក្រុមមួយចំនួន និងការតែងតាំងអ្នកសំរបសំរួលម្នាក់



ការពិភាក្សារវាងតំណាងសហគមន៍នេសាទជាមួយមន្ត្រីជលផល ស្តីពីការងារគ្រប់គ្រងដែននេសាទដោយផ្អែកលើការកែទំរង់គោលនយោបាយគ្រប់គ្រងវិស័យជលផលរបស់រាជរដ្ឋាភិបាល




ការពិភាក្សារវាងសមាជិកសហគមន៍នេសាទជាមួយមន្ត្រីជលផល

អំពីបទល្មើសនេសាទនៅក្នុងភូមិ



ការសំរេចចិត្តរបស់សហគមន៍នេសាទ

ដោយរៀបចំបង្កើតតំបន់អភិរក្សមួយ នៅក្នុងបឹងរបស់ខ្លួន គឺជាការអនុវត្តន៍សកម្មភាពមួយ

ក្នុងចំណោមសកម្មភាពជាច្រើននៅក្នុងផែនការសហគមន៍នេសាទ



# ផែនការគ្រប់គ្រងផលផល

## ដកស្រង់ចេញពីផែនការរួមក្នុងការគ្រប់គ្រងផលផលនៃសហពន្ធ័នេសាទអាងទឹកបឹងជន្លេន

(វិច្ឆិកា ២០០១)

បឹងជន្លេនជាដែននេសាទសាធារណៈ ដែលគ្មានការជួលទៅអោយបុគ្គលណាមួយ ឬ ប្រមូលថ្លៃឈ្នួលពីតំបន់នេះឡើយ ។ ដូច្នេះហើយបានជាគ្មានការត្រួតពិនិត្យ និងគ្មានការគ្រប់គ្រងផលផលអោយបានល្អប្រសើរនៅក្នុងបឹងនេះ ។ អ្នកភូមិដែលនៅជុំវិញអាងទឹកបឹងជន្លេនបានបញ្ជាក់ថា ផលត្រីមានការថយចុះ និង ពូជត្រីមួយចំនួនមានការបាត់បង់ដែលនេះគឺជាបញ្ហាចំបងកើតមាននៅក្នុងអាងទឹកនេះ។ អ្នកភូមិទាំងនោះ បានលើកហេតុផលជាច្រើនពីការធ្វើនេសាទ និងកត្តាដែលធ្វើឱ្យធនធានផលផលថយចុះដូចជា ការប្រើឧបករណ៍ឆក់ អួនហ៊ុំសំណាញ់ក្រឡាតូច ត្រីងាប់ដោយសារទឹកកខ្វក់ពីផ្សារ និង ពីសាលារៀនដែលនៅជិតអាងទឹក ថ្នាំពុលបណ្តាលមកពីការដាំឈូក អាងទឹកកាន់តែរាក់បណ្តាលមកពីល្បាប់ហូរចូល និង ការចិញ្ចឹមទានៅក្នុងអាង ។ ដើម្បីទប់ស្កាត់បញ្ហាទាំងអស់នោះ សហពន្ធ័សហគមន៍នេសាទអាងទឹកបឹងជន្លេនបានរៀបចំផែនការនៅក្នុងខែវិច្ឆិកា ឆ្នាំ ២០០១ ។ ខាងក្រោមនេះ គឺជាផ្នែកខ្លះៗនៃផែនការដែលបានរៀបចំឡើង។

### ទិសដៅនៃការគ្រប់គ្រង

បញ្ឈប់ការថយចុះនៃផលត្រី និង ទប់ស្កាត់ការបាត់បង់ពូជត្រីនៅក្នុងអាងទឹកបឹងជន្លេន ។

**សកម្មភាពទី ១:** រៀបចំក្រុមល្បាតនៅក្នុងចំណោមសមាជិកសហគមន៍ ដើម្បីជំរុញការអនុវត្តន៍នូវបទបញ្ញត្តិនៃការធ្វើនេសាទ ដោយឃ្លាំមើល និង ចូលរួមហាមឃាត់សកម្មភាពនេសាទដែលបំផ្លិចបំផ្លាញដូចជាការប្រើឧបករណ៍ឆក់ អួនហ៊ុំ និង សំណាញ់ក្រឡាតូចជាដើម ។

**សកម្មភាពទី ២:** ផ្សព្វផ្សាយបទបញ្ញត្តិនៃការធ្វើនេសាទតាមរយៈការដាក់ផ្លាកសញ្ញា ប្រជុំជាមួយបណ្តាអ្នកពាក់ពន្ធ័ជាដើម ។

**សកម្មភាពទី ៣:** រៀបចំវគ្គបណ្តុះបណ្តាល ដែលពិភាក្សាអំពីផលប៉ះពាល់ជាអវិជ្ជមាននៃការប្រើប្រាស់ឧបករណ៍ឆក់ អួនហ៊ុំ សំណាញ់ក្រឡាតូច និង បរិស្ថាន នៅក្នុងអាងទឹក ។

**សកម្មភាពទី ៤:** ចងក្រងឯកសារបទពិសោធន៍អំពីការងាប់របស់ត្រី និង ធ្វើសហប្រតិបត្តិការជាមួយអ្នកជំនាញ ដើម្បីស្រាវជ្រាវលើករណីទាំងនោះ ។

**សកម្មភាពទី ៥:** បង្កើតតំបន់អភិរក្សនៅក្នុងអាងទឹក និង ប្រកាសមិនអនុញ្ញាតអោយនេសាទនៅតំបន់អភិរក្សនោះ ។

# គោលការណ៍ណែនាំជាមូលដ្ឋានសំរាប់រៀបចំសេចក្តីព្រាងលក្ខន្តិកៈសហគមន៍នេសាទ

លក្ខន្តិកៈ គឺជាការចងក្រងគំនិតជាច្រើន ជាយោបល់រួមមួយស្របតាមច្បាប់ ហើយត្រូវបានកំណត់សំរាប់អង្គភាព រឺស្ថាប័នមួយ។ គំនិតទាំងនេះត្រូវបានបង្កើតឡើង ដោយសមាជិកនៃអង្គភាព រឺស្ថាប័ននោះ ក្នុងគោលបំណងផ្តល់ទិសដៅណែនាំក្នុងការធ្វើការសំរេច និងអនុវត្តសកម្មភាពរបស់អង្គភាពពួកគេ ។ លក្ខន្តិកៈអាចត្រូវបានធ្វើឡើងជាលក្ខណៈច្បាស់លាស់ រឺជាលក្ខណៈទូទៅក៏បាន គឺអាស្រ័យទៅតាមគោលបំណងរបស់សមាជិកដែលចង់បាន ហើយនិងអាស្រ័យទៅលើអ្វីដែលពួកគេគិតថាចាំបាច់។ ចំណុចខាងក្រោមនេះ ជាគោលការណ៍ណែនាំខ្លះៗ សំរាប់សេចក្តីព្រាងលក្ខន្តិកៈសហគមន៍នេសាទរបស់អ្នក ។

## គោលបំណងសហគមន៍ និង ឈ្មោះ

- តើអ្នកបង្កើតសហគមន៍ក្នុងគោលបំណងអ្វី?
- តើអ្នកចង់ដាក់ឈ្មោះសហគមន៍របស់អ្នកឈ្មោះអ្វី ?

## សកម្មភាព

- តើសកម្មភាពអ្វីខ្លះដែលអ្នកចង់ធ្វើ ដើម្បីសំរេចគោលបំណងក្នុងការបង្កើតសហគមន៍?

## ទីកន្លែងប្រតិបត្តិការ

- តើទីស្នាក់ការជាមូលដ្ឋានរបស់សហគមន៍គួរដាក់នៅកន្លែងណា? ហើយប្រតិបត្តិការនៅកន្លែងណាខ្លះ?

## សមាជិកភាពរបស់សហគមន៍

- តើអ្នកណាខ្លះអាចចូលជាសមាជិកសហគមន៍បាន (ឧ.បុរស ស្ត្រី តើត្រូវគិតពីអាយុដែរឬទេ? ជាអ្នកធ្វើនេសាទពេញម៉ោង និងមិនពេញម៉ោង? តើអ្នកនោះមកពីណា រឺផ្ទះសម្បែងនៅឯណា? ។ល។)
- តើការចូលជាសមាជិកភាពនេះ ជាបុគ្គលម្នាក់ រឺជាគ្រួសារ?
- តើត្រូវដំណើរការយ៉ាងណា ដើម្បីអោយអ្នកណាម្នាក់ក្លាយជាសមាជិកសហគមន៍?
- តើលក្ខខណ្ឌអ្វីខ្លះ ដែលបញ្ឈប់អ្នកណាម្នាក់ពីសមាជិកភាព?

## រចនាសម្ព័ន្ធរបស់សហគមន៍

- តើអ្នកណាជាអ្នកមានសិទ្ធិសំរេច និង ធ្វើគោលការណ៍ផែនការរបស់សហគមន៍?
- តើអ្នកណាជាអ្នកអនុវត្តគោលការណ៍ និងផែនការទាំងនេះ? (ជាបុគ្គលម្នាក់? ជាក្រុមតូច? ។ល។)
- តើមានការទទួលខុសត្រូវចំពោះភារកិច្ចអ្វីខ្លះ?

**ការជ្រើសរើសអ្នកដឹកនាំ (គណៈកម្មការសហគមន៍)**

- តើអ្នកណាខ្លះអាចក្លាយជាអ្នកដឹកនាំ? ហើយតើអ្នកទាំងនោះត្រូវជ្រើសរើសយ៉ាងដូចម្តេច?
- តើអ្នកដឹកនាំទាំងនោះមានតួនាទីអ្វី? ហើយមានភារកិច្ច និង មុខងារធ្វើអ្វីខ្លះ?
- តើកំណត់រយៈពេលជាអ្នកដឹកនាំនេះប៉ុន្មានឆ្នាំ?
- តើមានលក្ខខណ្ឌនៃការលាឈប់ និង បណ្តេញចេញគណៈកម្មការយ៉ាងដូចម្តេច?

**ការប្រជុំ**

- តើត្រូវធ្វើការប្រជុំនៅពេលណា និង ប៉ុន្មានដងក្នុង១ឆ្នាំ?
- តើកិច្ចប្រជុំនេះនឹងពិភាក្សាពីអ្វី?

**សិទ្ធិ និងការទទួលខុសត្រូវរបស់សមាជិក**

តើសមាជិកម្នាក់ៗត្រូវមានភារកិច្ចអ្វីខ្លះ?

ឧទាហរណ៍:

- ចូលរួមក្នុងការបង្កើតគោលការណ៍ ផែនការ និងអនុវត្តផែនការរបស់សហគមន៍នេសាទ។
- បង់ថវិកាវិភាគទានប្រាក់បំណាច់ផ្សេងៗ (ប្រសិនបើសំរេចថាគួរមានប្រាក់បំណាច់ផ្សេងៗទាំងនេះ) ដូចជាការបង់ប្រាក់ ក្នុងនាមជាសមាជិក ការបង់ប្រាក់ប្រចាំឆ្នាំ ។ល។
- ចូលរួមក្នុងគ្រប់សកម្មភាពក្នុងនាមជាសមាជិក ។ ឧ. ដូចជាចូលរួមប្រជុំ រឺ វគ្គបណ្តុះបណ្តាល ។ល។
- អាចក្លាយជាអ្នកដឹកនាំ ប្រសិនបើត្រូវបានជ្រើសរើសដោយសមាជិក
- ចូលរួមក្នុងការបោះឆ្នោតជ្រើសរើសអ្នកដឹកនាំ
- ចូលរួមជ្រើសរើសសកម្មភាពក្នុងផែនការមកអនុវត្ត។

**ការធ្វើការសំរេចចិត្ត**

- តើការសំរេចអ្វីមួយរបស់សហគមន៍ត្រូវធ្វើឡើងតាមរបៀបណា? (ឧ. ធ្វើការពិគ្រោះយោបល់ជាមួយសមាជិក និងអ្នកពាក់ព័ន្ធ ឬ ដោយអ្នកដឹកនាំតែឯង?)
- តើសេចក្តីសំរេចនេះត្រូវផ្អែកលើគោលការណ៍យ៉ាងដូចម្តេច? (ឧ. ដោយមតិទូទៅ ដោយមតិភាគច្រើនដែលមានសំលេងពីរភាគបីនៃសមាជិកជាដើម ។ល។)

**ថវិកា និងហិរញ្ញវត្ថុ**

តើសហគមន៍បានថវិកាពីប្រភពណា និង បានមកយ៉ាងដូចម្តេចដើម្បីទ្រទ្រង់សកម្មភាពរបស់ខ្លួន?

# អង្គការដែលបានផ្តួចផ្តើមធ្វើការជាមួយសហគមន៍នេសាទនៅក្នុងប្រទេសកម្ពុជា

| ឈ្មោះអង្គការ/គំរោង | សកម្មភាព | អស័យដ្ឋានទំនាក់ទំនង |
|---|---|---|
| **ខេត្តបន្ទាយមានជ័យ** | | |
| VSG (ក្រុមគាំទ្រភូមិ) កម្មវិធីសមាហរន្តកម្មអភិវឌ្ឍន៍ (ឥណទានធនាគារ ស្រូវ ឥស្សូមតិ កសាងសមត្ថភាព។ល។) ។ កម្មវិធីនេះក៏មាននៅខេត្តបាត់ដំបងដែរ ។ | កសាងសមត្ថភាពសហគមន៍នេសាទ ២០០០- បច្ចុប្បន្ន | អ្នកស្រី រស់ ឆវីវណ្ណ ឃុំសំបូរ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ទូរស័ព្ទ: ០១២ ៩១៥ ៥៤០ ០៩៣ ៩៩២ ៥៨៣ |
| **ខេត្តបាត់ដំបង** | | |
| AS (អភិវឌ្ឍន៍ស្ត្រី) កម្មវិធីគ្រប់គ្រងធនធានធម្មជាតិ | បង្កើតសហគមន៍នេសាទ កសាងសមត្ថភាព អប់រំបរិស្ថាន ១៩៩៩- បច្ចុប្បន្ន | អ្នកស្រីថោង ថាវីរ៉ន ផ្លូវលេខ៣ ភូមិកំពង់ក្របី ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ទូរស័ព្ទ: ០៩៣ ៩៩២ ៤៣៣ |
| KAWP (ក្រុមអភិវឌ្ឍន៍ភូមិ) កម្មវិធីលើកស្ទួយសង្គមស៊ីវិលនៅតាមលំដាប់ភូមិនិងក្រៅភូមិ និងកម្មវិធីសំរបសំរួលសហគមន៍ នេសាទ | បង្កើតសហគមន៍ និង កសាងសមត្ថភាព ២០០១- បច្ចុប្បន្ន | អ្នកស្រី នូ រ៉ាវី ភូមិវត្តគ ឃុំវត្តគ ស្រុកបាត់ដំបង ទូរស័ព្ទ: ០១២ ៨៥៦ ៣០៣ |
| LEUCAENA (គំរោងបឹងទន្លេសាប) | បង្កើតសហគមន៍នេសាទ កសាងសមត្ថភាព អប់រំបរិស្ថាន ២០០១- បច្ចុប្បន្ន | លោក ឡាយ ឡេង ផ្ទះ២២ ក្រុម១ ភូមិរតនៈ ឃុំរតនៈ ស្រុកបាត់ដំបង ទូរស័ព្ទ: ០១៦ ៩៣៣១២១ |
| CFDS (សេវាអភិវឌ្ឍន៍គ្រួសារកម្ពុជា) គំរោងរៀបចំសហគមន៍នេ-សាទ ។ កម្មវិធីនេះក៏មាននៅខេត្តពោធិសាត់ដែរ ។ | បង្កើតសហគមន៍នេសាទ ២០០១- បច្ចុប្បន្ន | លោក គីត ប៊ុនថេត ភូមិរំចេក ៤ ឃុំរតនៈ ស្រុកបាត់ដំបង ទូរស័ព្ទ: ០១២ ៩៩៨ ៤២៥ |
| **ខេត្តកំពង់ឆ្នាំង** | | |
| CCD (អភិវឌ្ឍន៍សមត្ថភាពសហគមន៍) កម្មវិធីអភិវឌ្ឍន៍សហគមន៍នេសាទ (កម្មវិធីនេះក៏មាននៅខេត្តបាត់ដំបង កំពង់ធំ បន្ទាយមានជ័យ តាកែវ) | កសាងសមត្ថភាពសហគមន៍នេសាទ ២០០០- បច្ចុប្បន្ន | អ្នកស្រី យឹម ឡេងយី ភូមិខ្សាម ឃុំខ្សាម ស្រុកកំពង់ឆ្នាំង ទូរស័ព្ទ: ០១២ ៩៦៤ ៤៣២ |

| | | |
|---|---|---|
| **ខេត្តកំពង់ចាម** | | |
| NAS (អ្នកអភិវឌ្ឍន៍សហគមន៍) កម្មវិធីសមាហរន្តកម្មអភិវឌ្ឍន៍សហគមន៍ | បង្កើតសហគមន៍នេសាទ កសាងសមត្ថភាព ២០០១- បច្ចុប្បន្ន | លោក គីត ថេង ផ្ទះ១២២ ភូមិ២ ផ្លូវទួលត្បែង ឃុំវាលវង់ ទូរស័ព្ទៈ ០១២ ៩៨៥ ៥១២ |
| ADHOC (សមាគមការពារសិទ្ធិមនុស្ស) អនុគណកម្មការនេសាទ | អភិរក្សធនធានជលផល កសាងសមត្ថភាព ដោះស្រាយជំលោះ ២០០១- បច្ចុប្បន្ន | លោក កែវ សុផាន ភូមិ៧ ឃុំកំពង់ចាម ស្រុកកំពង់ចាម ទូរស័ព្ទៈ០៤២ ៩៤១ ៣២៦ ០១២ ៧៥៧ ០៦១ |
| **ខេត្តកំពង់ធំ** | | |
| GTZ (អង្គការសហប្រតិបត្តិការបច្ចេកទេសសហពន្ធ័អាល្លឺម៉ង់) កម្មវិធីអភិវឌ្ឍន៍ជនបទ និង គ្រប់គ្រងធន ធានធម្មជាតិ | បង្កើតសហគមន៍ កសាងសមត្ថភាព ១៩៩៩- បច្ចុប្បន្ន | កែវ វុធថា ស្រុកសន្ទុក ទូរស័ព្ទៈ ០១១ ៨៨២ ០៨៣ លី កាណារ៉ា ស្រុកស្ទឹងសែន ទូរស័ព្ទៈ ០១២ ៨៨៨ ០០៣ ហាំ ហ៊ុន នៅស្រុកស្ទួង ទូរស័ព្ទៈ ០១២ ៧២៨ ៦១០ |
| AACK (អង្គការអភិវឌ្ឍន៍ជនក្រីក្រ) កម្មវិធីអភិវឌ្ឍន៍សហគមន៍ | សំរបសំរួលការបង្កើតសហគមន៍នេសាទ សុខភាព និង ស្បៀង ១៩៩៦- បច្ចុប្បន្ន | លោក យឹម ឡាម ឃុំស្រយ៉ូវ ស្រុកស្ទឹងសែន ទូរស័ព្ទៈ ០១២ ៩៦០ ១៤០ |
| COWS (អង្គការទ្រទ្រង់ស្ត្រីខ្មែរ) គំរោងគ្រប់គ្រងធនធានធម្មជាតិ | បង្កើតសហគមន៍នេសាទ កសាងសមត្ថភាព ២០០២-បច្ចុប្បន្ន | អ្នកស្រី ឈួន ចន្ទពុទ្ធធារី ភូមិកំពង់ធំ ឃុំកំពង់រទេះ ស្រុកស្ទឹងសែន ទូរស័ព្ទៈ ០១២ ៧៨៤ ១២២ |
| WFD (អង្គការអភិវឌ្ឍន៍គ្រួសារទន់ខ្សោយ) កម្មវិធីអភិវឌ្ឍន៍ជនបទ | បង្កើតសហគមន៍នេសាទ ២០០១- បច្ចុប្បន្ន | អ្នកស្រី លី ឡាវុង ទូរស័ព្ទៈ ០១២ ៨៦៥ ៤០៩ |
| CREDO (អង្គការអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ) កម្មវិធីអភិវឌ្ឍន៍ជនបទ | បង្កើតសហគមន៍នេសាទ ឥណទាន តស៊ូមតិ ២០០២- បច្ចុប្បន្ន | លោក ឡុង ឈាន ឃុំតាំងកសាង ស្រុកសន្ទុក ទូរស័ព្ទៈ ០១២ ៩០៨ ៦៦៩ |

| | | |
|---|---|---|
| CWS<br>( គ្រីស្តសាសនាបំរើពិភពលោក)<br>គំរោងគ្រប់គ្រងធនធានជលផល | បង្កើតសហគមន៍នេសាទ<br>កសាងសមត្ថភាព<br>២០០១- បច្ចុប្បន្ន | លោក ឯម ចាន់ណារិទ្ធ<br>ភូមិដីរីជាន់ខ្លា ឃុំដីរី ជាន់ខ្លា<br>ស្រុកស្ទឹងសែន<br>ទូរស័ព្ទ: ០១២ ៧០៨ ១៩៣ |
| **ខេត្តកណ្តាល** | | |
| គ្រោងការគ្រប់គ្រងជលផលនៅអាងទឹកនៃអាងទន្លេមេគង្គ ជំហានទី២/ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទនៃនាយកដ្ឋានជលផល ( កម្មវិធីនេះ ក៏មាននៅខេត្តកំពង់ចាមដែរ) | រៀបចំសហគមន៍នេសាទ<br>លើកកំពស់សមត្ថភាព<br>២០០០- បច្ចុប្បន្ន | ប្រាជ្ញ សុគន្ធី , ស៊ឹង សុគន្ធធា<br>ទូរស័ព្ទ: ០២៣ ២១០ ១៥៤<br>០១២ ៧៣៣ ៩៣២<br>០១២ ៦៦៨ ៣១០<br>០១៦ ៨៩០ ៥៥៥ |
| **ខេត្តកំពង់ស្ពឺ** | | |
| AIT/DoF អង្គការ អេ អាយ ធី នៃនាយកដ្ឋានជលផល<br>កម្មវិធីចិញ្ចឹមត្រី | សហគមន៍ជំរកត្រី<br>២០០២- បច្ចុប្បន្ន | លោក ហាវ វិសិទ្ធ<br>មន្ត្រីនាយកដ្ឋានជលផល<br>ទូរស័ព្ទ: ០១២ ៩១៨ ៤៨៧ |
| **ខេត្តកោះកុង** | | |
| PMMR( មជ្ឈមណ្ឌលស្រាវជ្រាវដើម្បីអភិវឌ្ឍន៍អន្តរជាតិ) ក្រសួងបរិស្ថាន កម្មវិធីចូលរួមក្នុងការគ្រប់គ្រងតំបន់ឆ្នេរ | រៀបចំសហគមន៍នេសាទ<br>អភិវឌ្ឍន៍ជីវភាពឱ្យមាននិរន្តភាព ជាដើម<br>២០០២-បច្ចុប្បន្ន | លោកជា ពេជរតនា<br>ភូមិ៣ ឃុំស្មាច់មានជ័យ<br>ស្រុកស្មាច់មានជ័យ<br>ទូរស័ព្ទ:០១២ ៩៧៦ ៤៥៣ |
| **ខេត្តកំពង់សោម** | | |
| រាម | រៀបចំសហគមន៍នេសាទ<br>និងលើកកំពស់សមត្ថភាព | លោក ស៊ុយ ធា<br>ទូរស័ព្ទ: ០១៦ ៨៨៦ ៤២៥ |
| **ខេត្តពោធិសាត់** | | |
| EPDO<br>( អង្គការការពារបរិស្ថានដើម្បីអភិវឌ្ឍន៍) កម្មវិធីលើកទឹកចិត្តសហគមន៍ ក្នុងការអភិរក្សព្រៃឈើ | រៀបចំសហគមន៍នេសាទ<br>និងលើកកំពស់សមត្ថភាព<br>១៩៩៩- បច្ចុប្បន្ន | លោក ព្រំ អ៊ុត ក្រុម២<br>ភូមិពាលនិច ឃុំពុទ្ធាព្រៃ<br>ស្រុកសំពៅមាស<br>ទូរស័ព្ទ: ០៥២ ៩៥១ ៤២៦ |
| **ខេត្តសៀមរាប** | | |
| FAO ( អង្គការស្បៀងនិងកសិកម្មនៃអង្គការសហប្រជាជាតិ) ចូលរួមគ្រប់គ្រងធនធានធម្មជាតិក្នុងតំបន់ទន្លេសាប | រៀបចំសហគមន៍នេសាទ<br>កសាងសមត្ថភាព<br>ផ្សព្វផ្សាយពត៌មាន<br>១៩៩៥- បច្ចុប្បន្ន | ចាន់ តុង មន្ត្រីជលផល<br>ខេត្តសៀមរាប<br>ទូរស័ព្ទ: ០១២ ៨៨០ ៧៦៣<br>០៦៣ ៩៦៣ ៥២៥ |

